# សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

# បទបញ្ជាផ្ទៃក្នុងនិស្សិតស.វ.ស

## ឆ្នាំ២០២១




**អាសយដ្ឋាន និងទំនាក់ទំនង៖**
-ទីតាំងទី១៖ ឡូត៍លេខ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
-ទីតាំងទី២៖ ឡូត៍លេខ៣០១ មហាវិថីយោធពលខេមរៈភូមិន្ទ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ (២៧១)
-ទីតាំងទី៣៖ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទំនាក់ទំនង៖
ប្រអប់សំបុត្រលេខ២០ ទូរស័ព្ទ ២៣(៨៥៥)៤៣០ ៥៥៩ ទូរសារ ៤៣០១៨៦(៨៥៥)
អ៊ីម៉ែល info@uhs.edu.kh គេហទំព័រ www.uhs.edu.kh Facebook: www.facebook.com/uhs.edu.kh
Youtube: www.youtube.com/UHSEduKh , Telegram Channel: https://t.me/UHSEduKh

## អារម្ភកថា

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (ស.វ.ស) គឺជាសាកលវិទ្យាល័យដែលមានវ័យចំណាស់ជាងគេ និងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងវិស័យសុខាភិបាលតាំងពីឆ្នាំ១៩៤៦មក។ ផែនការយុទ្ធសាស្ត្ររបស់ស.វ.សឆ្នាំ២០១៩-២០២៣បានបង្ហាញយ៉ាងច្បាស់ថា ស.វ.ស មានចក្ខុវិស័យដើម្បីក្លាយជាគ្រឹះស្ថានឧត្តមសិក្សាជាតិឈានមុខគេបង្អស់ក្នុងវិស័យវិទ្យាសាស្ត្រសុខាភិបាល ប្រកបដោយឧត្តមភាពក្នុងការបណ្តុះបណ្តាល ការស្រាវជ្រាវ នវានុវត្តន៍ និងការផ្តល់សេវាសុខាភិបាល។ ដើម្បីសម្រេចចក្ខុវិស័យខាងលើនេះ ស.វ.សយល់យ៉ាងច្បាស់ថា "កត្តានិស្សិត" គឺជាកត្តាដ៏សំខាន់មួយក្នុងចំណោមកត្តាសំខាន់ៗដទៃទៀតដែលត្រូវចូលរួមសកម្មភាពជាមួយមហាគ្រួសារស.វ.សយើងទាំងអស់គ្នា។ អាស្រ័យហេតុនេះ បានជាសាកលវិទ្យាល័យផ្តល់អាទិភាពដល់ការពង្រឹងគុណភាពសេវានានាដើម្បីឱ្យនិស្សិតទទួលបាននូវការបណ្តុះបណ្តាលប្រកបដោយគុណភាព និងដើម្បីធានាលទ្ធផលសិក្សារំពឹងទុកទាំងវិជ្ជាសម្បទា ទាំងបំណិនសម្បទា និងទាំងចរិយាសម្បទារបស់និស្សិតស.វ.សទោះបីក្នុងបរិបទនៃការរាតត្បាតជាសាកលនៃជំងឺកូវីដ ១៩នេះ។

ឆ្លៀតក្នុងឱកាសនៃការដាក់ឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងថ្មីឆ្នាំ២០២១នេះ ខ្ញុំសូមស្វាគមន៍ និងអបអរសាទរជាបឋមដល់ប្អូនៗនិស្សិតដែលនឹងប្រឡងជាប់ចូលរៀន និងក្លាយជាសមាជិករបស់មហាគ្រួសារសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលក្នុងពេលខាងមុខនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អាណាព្យាបាលរបស់ប្អូនៗនិស្សិតដែលផ្តល់ការទុកចិត្ត និងបានជ្រើសរើសស.វ.សជាមជ្ឈដ្ឋានបណ្តុះបណ្តាលវិស័យសុខាភិបាលដល់ប្អូនៗទាំងអស់គ្នា។ ខ្ញុំក៏សូមថ្លែងអំណរគុណជាថ្មីផងដែរដល់និស្សិតស.វ.សចាប់ពីថ្នាក់ឆ្នាំសិក្សាទី២ឡើងទៅទាំងអស់ដែលជាសមាជិកគ្រួសារស.វ.ស និងដែលបានផ្តល់ការទុកចិត្តចូលរួមក្នុងបេសកកម្មរបស់ស.វ.ស។

បទបញ្ជាផ្ទៃក្នុងនិស្សិតឆ្នាំ២០២១ គឺជាជំនួយស្មារតីសង្ខេបដល់ប្អូនៗនិស្សិតក្នុងការស្វែងយល់ពីទិដ្ឋភាពរួមរបស់ស.វ.សផង ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាល និងការវាយតម្លៃនានាផង ក៏ដូចជាការបរិយាយចំណុចសំខាន់នានាដែលនិស្សិតត្រូវប្រកាន់យកក្នុងការអនុវត្ត និងក្នុងការរក្សាតម្លៃនានារបស់និស្សិតស.វ.សសម្រាប់ដំណើរការសិក្សានៅក្នុងស.វ.ស ស្របជាមួយនឹងខ្លឹមសារនានាចែងក្នុងឯកសារ "សៀវភៅណែនាំនិស្សិត" ឆ្នាំ២០១៩ផងដែរ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្នុងអំឡុងពេលដែលប្អូនៗនិស្សិតសិក្សានៅក្នុងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងក្រោយពេលបញ្ចប់ការសិក្សា ប្អូនៗនឹងទទួលបាននូវបទពិសោធន៍ជាទីមោទនភាពជាមួយនឹងការវិវត្តទៅមុខជានិច្ចរបស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលនៅក្នុងការបង្រៀន ការសិក្សា ការស្រាវជ្រាវ នវានុវត្តន៍ និងការផ្តល់សេវាសុខាភិបាល។

ដោយសេចក្តីសង្ឃឹមលើប្អូនៗទាំងអស់ដែលជាអនាគតក្នុងវិស័យសុខាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ..................ខែ..............ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**សាកលវិទ្យាធិការ**

**សាស្ត្រាចារ្យ.សាផុន_វឌ្ឍនះ**

# មាតិកា


អារម្ភកថា ........................................ 2

ផ្នែកទី ១ ៖ លក្ខខណ្ឌនៃការចុះឈ្មោះចូលរៀន និងបង់ថ្លៃសិក្សា ........................................ 5

ប្រការ ១ ៖ ការចុះឈ្មោះចូលរៀន ........................................ 5

ផ្នែកទី ២ ៖ អំពីឯកសណ្ឋាន និងការរៀបចំខ្លួនក្នុងពេលសិក្សា និង ពិធីបុណ្យ ........................................ 6

ប្រការ ២ ៖ ឯកសណ្ឋានក្នុងពេលសិក្សា ........................................ 6

ប្រការ ៣ ៖ ឯកសណ្ឋានក្នុងពិធីផ្សេងៗ ........................................ 6

ប្រការ ៤ ៖ សក់ ........................................ 6

ផ្នែកទី ៣ ៖ អំពីការសិក្សា ........................................ 7

ប្រការ ៥ ៖ ការសិក្សា ........................................ 7

ប្រការ ៦ ៖ ការរៀបចំថ្នាក់ ឬ ក្រុមសិក្សា ........................................ 7

ប្រការ ៧ ៖ ការប្តូរជំនាញ ឬ មហាវិទ្យាល័យ/សាលា ........................................ 7

ផ្នែកទី ៤ ៖ អំពីអវត្តមាន ការព្យួរការសិក្សា និងការលុបឈ្មោះ ........................................ 7

ប្រការ ៨ ៖ អវត្តមាន ........................................ 7

ប្រការ ៩ ៖ ការព្យួរការសិក្សា ........................................ 8

ប្រការ ១០ ៖ ការលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិត ........................................ 9

ប្រការ ១១ ៖ ការកំណត់លក្ខខណ្ឌ "ត្រួតថ្នាក់" ........................................ 9

ប្រការ ១២ ៖ ការកំណត់លក្ខខណ្ឌនៃ "ការបោះបង់ការសិក្សា" ........................................ 9

ផ្នែកទី ៥ ៖ អំពីវិន័យ និង សណ្តាប់ធ្នាប់ ........................................ 10

ប្រការ ១៣ ៖ ក្នុងបរិវេណសាកលវិទ្យាល័យ ........................................ 10

ប្រការ ១៤ ៖ ក្នុងថ្នាក់រៀនទ្រឹស្តី និងអនុវត្តបង្ហាញគ្រាប់ ........................................ 11

ប្រការ ១៥ ៖ ក្នុងបណ្ណាល័យ ........................................ 11

ផ្នែកទី ៦ ៖ អំពីការប្រឡង ........................................ 12

ប្រការ ១៦ ៖ មុនពេលប្រឡង ........................................ 12

ប្រការ ១៧ ៖ ពេលចូលប្រឡង ........................................ 12

ប្រការ ១៨ ៖ ក្នុងពេលប្រឡង ........................................ 12

ប្រការ ១៩ ៖ ការវាយតម្លៃនៃការប្រឡង ........................................ 13

ផ្នែកទី ៧៖ ពិន័យនៅពេលប្រឡង ........................................ 13

ប្រការ ២០ ៖ ករណីមានឯកសារ ឬ សំណៅផ្សេងៗ ........................................ 13

ប្រការ ២១ ៖ ការអង្គុយខុសលេខតុ/កុំព្យូទ័រ ឬ បញ្ចូលទិន្នន័យដែលមិនមែនជាទិន្នន័យរបស់សាមីខ្លួនក្នុងប្រព័ន្ធកុំព្យូទ័រ ........................................ 13

ប្រការ ២២ ៖ ការប្រគល់សន្លឹកកិច្ចការជាក្រដាស ........................................ 13

ប្រការ ២៣ ៖ ការប្រព្រឹត្តកំហុសនានាដែលផ្ទុយពីបទបញ្ជាផ្ទៃក្នុងនៃការប្រឡង ........................................ 13

ប្រការ ២៤ ៖ ករណីបង្កទំនាស់ក្នុងពេលប្រឡង ........................................ 13

ប្រការ ២៥ ៖ ការហែកចោលសន្លឹកកិច្ចការប្រឡង ឬការបង្កការខូចខាតសម្ភារៈប្រឡងដោយចេតនា ........................................ 14

ប្រការ ២៦ ៖ ការប្រឡងជំនួស ........................................ 14

ផ្នែកទី ៨ ៖ អំពី សិល្បៈ និង កីឡា ........................................ 14

ប្រការ ២៧ ៖ អំពីសិល្បៈ ........................................ 14

ប្រការ ២៨ ៖ អំពីកីឡា ..................... 14
ផ្នែកទី ៩ ៖ អំពីការចូលរួមក្នុងសកម្មភាពផ្សេងៗ ..................... 14
ប្រការ ២៩ ៖ ..................... 14
ប្រការ ៣០ ៖ ..................... 14
ប្រការ ៣១ ៖ ..................... 14
ផ្នែកទី ១០ ៖ ឱសានវាទនៃបញ្ញត្តិ ..................... 15
ប្រការ ៣២ ៖ ..................... 15
ប្រការ ៣៣ ៖ ..................... 15
ប្រការ ៣៤ ៖ ..................... 15

# បទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិត

**<u>យោង</u>៖** -បទបញ្ជាផ្ទៃក្នុងនិស្សិតរបស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០១៩។

-លិខិតលេខ៨៤៣ ស.វ.ស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីគោលការណ៍ជាប់ធ្លាក់របស់និស្សិតក្នុងការប្រឡងផ្សេងៗនៅស.វ.ស។

-លិខិតលេខ៣៣៩៥ ស.វ.ស ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីគោលការណ៍នៃការលុបឈ្មោះនិស្សិតចេញពីបញ្ជីនិស្សិតនៅស.វ.ស។

-គោលការណ៍ណែនាំស្តីពីការវាយតម្លៃសុពលភាពនិស្សិតមុនពេលប្រឡងរបស់ស.វ.សចុះខែវិច្ឆិកា ឆ្នាំ ២០១៧។

-លិខិតលេខ២៤៣១ ស.វ.ស ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីលក្ខខណ្ឌនៃការត្រួតថ្នាក់របស់និស្សិតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។

-សេចក្តីជូនដំណឹងលេខ២១៣៤ ស.វ.ស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ ស្តីពីគោលការណ៍ក្នុងការកំណត់ពិន្ទុសម្រាប់ការប្រឡងបញ្ចប់ការសិក្សារបស់ស.វ.ស។

-សៀវភៅណែនាំនិស្សិតបោះពុម្ពលើកទី២ ឆ្នាំ២០១៩ ចុះហត្ថលេខាដោយឯកឧត្តមសាស្ត្រាចារ្យសាកលវិទ្យាធិការ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩។

-របាយការណ៍ប្រជុំក្រុមប្រឹក្សាដឹកនាំប្រតិបត្តិស.វ.សថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ស្តីពីការកំណត់លក្ខខណ្ឌត្រួតថ្នាក់ និងបោះបង់ការសិក្សារបស់និស្សិតស.វ.ស។

## ផ្នែកទី ១
## លក្ខខណ្ឌនៃការចុះឈ្មោះចូលរៀន និងបង់ថ្លៃសិក្សា

**ប្រការ ១ ៖ ការចុះឈ្មោះចូលរៀន**

និស្សិតស.វ.សគ្រប់ឆ្នាំសិក្សាត្រូវមកចុះឈ្មោះចូលរៀនរៀងរាល់ឆ្នាំសិក្សាតាមការកំណត់របស់ស.វ.ស។

* ការចុះឈ្មោះចូលរៀនតាមការកំណត់របស់ស.វ.ស និង/ឬតាមការកំណត់របស់គណៈកម្មាធិការប្រឡងថ្នាក់ជាតិ គឺជាការចាំបាច់ដើម្បីបញ្ជាក់ថានិស្សិតបានសម្រេចចិត្តចូលសិក្សា ឬបន្តការសិក្សានៅស.វ.ស។
* ចំពោះនិស្សិតថ្មីដែលពុំបានចុះឈ្មោះចូលរៀនតាមកាលបរិច្ឆេទកំណត់របស់គណៈកម្មាធិការប្រឡងថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលវិស័យសុខាភិបាល ឬតាមការកំណត់របស់គណៈកម្មការរបស់ស.វ.សនឹងត្រូវចាត់ទុកថា "បោះបង់ចោលការសិក្សា" ហើយមិនអាចមកចុះឈ្មោះចូលរៀនឡើងវិញនៅឆ្នាំសិក្សាក្រោយបានទេ។
* និស្សិតថ្មីដែលបានចុះឈ្មោះរួច តែមិនបានបង់ថ្លៃសិក្សាយ៉ាងយូរបំផុតត្រឹមបំណាច់ឆមាសទី១នៃឆ្នាំសិក្សា ឬតាមការជូនដំណឹងរបស់ស.វ.សនឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតស.វ.ស។
* ចំពោះការបង់ថ្លៃសិក្សាគឺជាករណីដោយឡែកពីការចុះឈ្មោះចូលរៀនដែលនិស្សិតត្រូវគោរពតាមគោលការណ៍នៃការបង់ថ្លៃសិក្សារបស់ស.វ.ស។ តម្លៃសិក្សា បែបបទនៃការបង់ថ្លៃសិក្សា និងការផាកពិន័យលើការបង់ថ្លៃសិក្សានឹងមានចែងក្នុងសេចក្តីជូនដំណឹងស្តីពីការបង់ថ្លៃសិក្សារបស់ស.វ.សដែលបិទនៅបញ្ជរបេឡាស.វ.ស។

## ផ្នែកទី ២
## អំពីឯកសណ្ឋាន និងការរៀបចំខ្លួនក្នុងពេលសិក្សា និង ពិធីបុណ្យ

**ប្រការ ២ ៖ ឯកសណ្ឋានក្នុងពេលសិក្សា**

ក. ក្នុងបរិវេណសាកលវិទ្យាល័យ និស្សិតគ្រប់រូបត្រូវ ៖

*ពាក់ប័ណ្ណសម្គាល់ខ្លួននិស្សិត។

*ត្រូវមានសម្លៀកបំពាក់ ៖

-បុរស ៖ ខោជើងវែង ពណ៌ទឹកប៊ិច ឬខ្មៅ និងអាវពណ៌ផ្ទៃមេឃ ហើយត្រូវស៊កអាវក្នុងខោ។

-នារី ៖ សំពត់ពណ៌ទឹកប៊ិច ឬខ្មៅ ពាក់កណ្ដាលស្មងជើងយ៉ាងតិច (សមរម្យ) និងអាវពណ៌ផ្ទៃមេឃ ហើយត្រូវស៊កអាវក្នុងសំពត់។

*និស្សិតគ្រប់រូបត្រូវពាក់ស្បែកជើងសមរម្យ និងមិនអនុញ្ញាតឱ្យពាក់ស្បែកជើងផ្ទាត់ទេ ក្នុងបរិវេណស.វ.ស។

ខ. ពេលធ្វើកម្មសិក្សា និង ពេលសិក្សាអនុវត្តបង្ហាញត្រាប់ ៖

និស្សិតទាំងពីរភេទត្រូវពាក់ឯកសណ្ឋាន ឬ/និងសម្ភារៈផ្សេងទៀត តាមការណែនាំរបស់ទីតាំងកម្មសិក្សា និងតាមការណែនាំរបស់មន្ទីរពិសោធន៍បង្ហាញត្រាប់ដែលនិស្សិតត្រូវបំពេញ។

*ករណីនិស្សិតមិនគោរពតាមការណែនាំស្ដីពីឯកសណ្ឋាន និងវិន័យក្នុងពេលសិក្សា ក្នុងពេលធ្វើកម្មសិក្សា និងពេលសិក្សាអនុវត្តបង្ហាញត្រាប់ និស្សិតនោះមិនត្រូវអនុញ្ញាតឱ្យចូលសិក្សា ឬចូលធ្វើកម្មសិក្សា ឬ ការសិក្សាអនុវត្តបង្ហាញត្រាប់ទេ។

**ប្រការ ៣ ៖ ឯកសណ្ឋានក្នុងពិធីផ្សេងៗ**

+ ពិធីផ្លូវការ ៖

-បុរស ៖ ខោជើងវែងពណ៌ទឹកប៊ិច ឬខ្មៅលាត និងអាវពណ៌ផ្ទៃមេឃលាត ហើយត្រូវស៊កអាវក្នុងខោ។

-នារី ៖ សំពត់ពណ៌ទឹកប៊ិច ឬខ្មៅលាត ពាក់កណ្ដាលស្មងជើងយ៉ាងតិច (សមរម្យ) និងអាវពណ៌ផ្ទៃមេឃលាត ហើយត្រូវស៊កអាវក្នុងសំពត់។

*និស្សិតគ្រប់រូបត្រូវពាក់ពាក់ស្បែកជើងសមរម្យ និងមិនអនុញ្ញាតឱ្យពាក់ស្បែកជើងផ្ទាត់ទេ ក្នុងពិធីនានា។

*ករណីមានការណែនាំដោយឡែកក្នុងពិធីណាមួយ និស្សិតគ្រប់រូបត្រូវមានឯកសណ្ឋានតាមការណែនាំនោះ។

+ ពិធីបុណ្យ ៖

-បុរស និង នារី ៖ ស្លៀកពាក់សមរម្យ ឬ ប្រពៃណី។

*និស្សិតគ្រប់រូបត្រូវពាក់ពាក់ស្បែកជើងសមរម្យ និងមិនអនុញ្ញាតឱ្យពាក់ស្បែកជើងផ្ទាត់ទេក្នុងពិធីនានា។

*ករណីមានការណែនាំដោយឡែកក្នុងពិធីណាមួយ និស្សិតគ្រប់រូបត្រូវមានឯកសណ្ឋានតាមការណែនាំនោះ។

**ប្រការ ៤ ៖ សក់**

**-បុរស** ៖ ត្រូវមានសក់ខ្លីសមរម្យ និងមិនត្រូវលាបពណ៌សក់ខុសពីពណ៌ធម្មជាតិពីកំណើត។

**-នារី** ៖ ត្រូវចងសមរម្យ និងមិនត្រូវលាបពណ៌សក់ពណ៌ខុសពីពណ៌ធម្មជាតិពីកំណើត។

## ផ្នែកទី ៣
## អំពីការសិក្សា

**ប្រការ ៥ ៖ ការសិក្សា**

ក្នុងឆ្នាំសិក្សានីមួយៗ និស្សិតត្រូវគោរពតាមកាលវិភាគ ទាំងទ្រឹស្តី ទាំងការសិក្សាអនុវត្តបង្ហាញត្រាប់ និងទាំងកម្មសិក្សាដែលបានកំណត់ដោយមហាវិទ្យាល័យ/សាលា/ផ្នែក/ដេប៉ាតឺម៉ង់។

**ប្រការ ៦ ៖ ការរៀបចំថ្នាក់ ឬ ក្រុមសិក្សា**

ការរៀបចំជាថ្នាក់សិក្សា ជាក្រុមសិក្សាអនុវត្តត្រាប់ ឬជាក្រុមសម្រាប់ធ្វើកម្មសិក្សាក្នុងថ្នាក់នីមួយៗត្រូវកំណត់ដោយមហាវិទ្យាល័យ/សាលា/ផ្នែក/ដេប៉ាតឺម៉ង់។ រាល់ការសុំប្តូរក្រុមសិក្សា ឬថ្នាក់សិក្សា ត្រូវមានការអនុញ្ញាតពីព្រឹទ្ធបុរស/នាយក មហាវិទ្យាល័យ/សាលា ប្រធានផ្នែក/ដេប៉ាតឺម៉ង់។

**ប្រការ ៧ ៖ ការប្តូរជំនាញ ឬ មហាវិទ្យាល័យ/សាលា**

និស្សិតដែលបានប្រឡងជ្រើសរើសថ្នាក់ជាតិជាប់ចូលរៀននៅកម្មវិធីសិក្សាណាមួយនៅស.វ.ស មិនអាចប្តូរទៅរៀនកម្មវិធីសិក្សាផ្សេងបានឡើយ។

## ផ្នែកទី ៤
## អំពីអវត្តមាន ការព្យួរការសិក្សា និងការលុបឈ្មោះ

**ប្រការ ៨ ៖ អវត្តមាន**

រាល់ពេលអវត្តមាន និស្សិតគ្រប់រូបត្រូវសុំច្បាប់ជាលាយលក្ខអក្សរ យ៉ាងហោចណាស់មួយថ្ងៃមុនដោយសាមីខ្លួនផ្ទាល់នៅផ្នែកកិច្ចការនិស្សិតការិយាល័យរដ្ឋបាលនៃមហាវិទ្យាល័យ/សាលា/ដេប៉ាតឺម៉ង់/ផ្នែក ដោយបំពេញពាក្យសុំច្បាប់ឱ្យបានច្បាស់លាស់។ លើកលែងតែករណីកើតមានឡើងជាយថាហេតុផ្សេងៗដែលមិនបានដឹងមុន និស្សិត ឬតំណាងនិស្សិត ឬអាណាព្យាបាលនិស្សិតអាចសុំច្បាប់ឈប់ភ្លាមៗក្នុងករណីបន្ទាន់ ឬយ៉ាងយូរ៣ថ្ងៃរាប់ចាប់ពីថ្ងៃឈប់ដោយមានលិខិតបញ្ជាក់មូលហេតុច្បាស់លាស់នៅផ្នែកកិច្ចការនិស្សិតការិយាល័យរដ្ឋបាលនៃមហាវិទ្យាល័យ/សាលា/ដេប៉ាតឺម៉ង់/ផ្នែកដែលនិស្សិតកំពុងសិក្សា។

**ក.** ការឈប់ចំនួន៣ ថ្ងៃបន្តបន្ទាប់គ្នាដោយមិនបានសុំច្បាប់ និស្សិតត្រូវទទួលការស្តីបន្ទោសដោយមហាវិទ្យាល័យ/សាលា/ផ្នែក/ដេប៉ាតឺម៉ង់ និងជូនដំណឹងដល់អាណាព្យាបាល។

**ខ.** ការឈប់ចំនួន៣ ដងបន្តបន្ទាប់គ្នាលើមុខវិជ្ជាតែមួយ និស្សិតនឹងត្រូវទទួលការស្តីបន្ទោសដោយមហាវិទ្យាល័យ/សាលា/ផ្នែក/ដេប៉ាតឺម៉ង់ និងជូនដំណឹងដល់អាណាព្យាបាល។

**គ.** អវត្តមានលើសពី៣០ % រហូតត្រឹម៤០ % នៃម៉ោងសិក្សាទ្រឹស្តីនៃមុខវិជ្ជាណាមួយនៃឆមាសណាមួយ និស្សិតនឹងត្រូវបានចាត់ទុកថាធ្លាក់លើការសិក្សាទ្រឹស្តីនៃមុខវិជ្ជានោះក្នុងការប្រឡងឆមាសលើកទី១ដោយស្វ័យប្រវត្តិ ព្រមទាំងតម្រូវឱ្យប្រឡងសងឡើងវិញនៅលើកទី២ (2ème Session) តាមការកំណត់របស់ស.វ.ស និងដោយគោរពតាមលក្ខខណ្ឌសុពលភាពប្រឡងស.វ.ស។ រាល់ពិន្ទុនៃការប្រឡងលើកទី២នេះ សាកលវិទ្យាល័យកំណត់យកត្រឹមតែពិន្ទុអប្បបរមាសម្រាប់ជាប់ឡើងថ្នាក់ប៉ុណ្ណោះ ទៅបញ្ចូលនៅក្នុងព្រឹត្តិប័ត្រពិន្ទុ។ ករណីនិស្សិតធ្លាក់លើមុខវិជ្ជាណាមួយក្នុងការប្រឡងលើកទី២ និស្សិតត្រូវត្រួតថ្នាក់ឆ្នាំសិក្សានោះ។

**ឃ.** អវត្តមានលើសពី៤០% នៃម៉ោងសិក្សាទ្រឹស្តីនៃមុខវិជ្ជាណាមួយនៃឆមាសនីមួយៗ និស្សិតនឹងត្រូវត្រួតថ្នាក់ឆ្នាំសិក្សានោះដោយស្វ័យប្រវត្តិ។

**ង.**អវត្តមានលើសពី៣០%នៃម៉ោងអនុវត្តបង្ហាញគ្រាប់ទៅតាមទីតាំងដែលកំណត់ដោយស.វ.សនៃមុខវិជ្ជាណាមួយក្នុងឆមាសនីមួយៗ និស្សិតនឹងត្រូវត្រួតថ្នាក់ឆ្នាំសិក្សានោះដោយស្វ័យប្រវត្តិ។

**ច.**ការវាយតម្លៃអវត្តមានរបស់កម្មសិក្សាត្រូវធ្វើតាមសៀវភៅណែនាំកម្មសិក្សាដែលទាក់ទង ឬយោងតាមការណែនាំដោយឡែករបស់កម្មសិក្សានោះ។ ករណីកម្មសិក្សារបស់និស្សិតពុំមានសុពលភាព និស្សិតនឹងត្រូវត្រួតថ្នាក់ឆ្នាំសិក្សានោះដោយស្វ័យប្រវត្តិ។

**ចំណាំ ៖**

*ការឈប់មានច្បាប់ ១ ដង ចាត់ទុកជាការឈប់ ១/២ ដង។

*ការឈប់ឥតច្បាប់ ១ ដង ចាត់ទុកជាការឈប់ ១ ដង។

## ប្រការ ៩ ៖ ការព្យួរការសិក្សា

និស្សិតទាំងអស់មានសិទ្ធិសុំព្យួរការសិក្សា តែត្រូវគោរពលក្ខខណ្ឌដូចតទៅ ៖

ក.និស្សិតទាំងអស់អាចដាក់ពាក្យសុំព្យួរការសិក្សាបានលុះត្រាតែនិស្សិតទាំងនោះបានចុះឈ្មោះចូលរៀនជាមុនសិន។

ខ.រាល់ការសុំព្យួរការសិក្សានឹងចាត់ទុកជាការព្យួរការសិក្សាដែលមានរយៈពេល ១ឆ្នាំសិក្សា។

គ.គ្រប់និស្សិតដែលទទួលការអនុញ្ញាតការព្យួរការសិក្សានឹងត្រូវរៀនឡើងវិញគ្រប់មុខវិជ្ជានៃថ្នាក់ឆ្នាំសិក្សាដែលបានស្នើសុំព្យួរ នៅពេលនិស្សិតដាក់ពាក្យចូលរៀនឡើងវិញ។

ឃ.និស្សិតដែលសុំព្យួរការសិក្សាត្រូវនៅសល់ពេលវេលា (ឆ្នាំ) គ្រប់គ្រាន់សម្រាប់បញ្ចប់ការសិក្សាយោងតាមកម្មវិធីសិក្សាថ្នាក់ជាតិដែលពាក់ព័ន្ធ។

ង.ការព្យួរការសិក្សាត្រូវធ្វើនៅពេលចុះឈ្មោះចូលរៀន។ ប្រសិនបើការព្យួរការសិក្សាធ្វើឡើងក្រោយពីបង់ថ្លៃ ឬបង់សិទ្ធិសុំចូលរៀនរួច សាកលវិទ្យាល័យមិនបង្វិលថវិកានោះជូនវិញទេ។

ច.និស្សិតដែលសុំព្យួរការសិក្សា ត្រូវមានមូលហេតុច្បាស់លាស់ និងមានការឯកភាពពីអាណាព្យាបាលជាលាយលក្ខអក្សរ។

ឆ.ក្នុងអំឡុងពេលសិក្សា ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់ក្រោយបរិញ្ញាបត្រ និស្សិតអាចសុំព្យួរការសិក្សាបានតែ ២ដងគត់ ហើយមិនបន្តបន្ទាប់គ្នា។ ប៉ុន្តែចំពោះនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ ការព្យួរការសិក្សា ត្រូវគោរពតាមលក្ខខណ្ឌដោយឡែកយោងតាមកម្មវិធីសិក្សាដែលនិស្សិតសិក្សានោះ។

ជ.និស្សិតដែល "ព្យួរការសិក្សា" ខាងលើនេះ ដែលមិនបានបង់ថ្លៃសិក្សាពេញ១ឆ្នាំ ដោយមូលហេតុសមស្របណាមួយ នៅពេលចុះឈ្មោះចូលរៀនវិញជាថ្មី ប្រសិនបើទទួលការអនុញ្ញាតពីស.វ.ស និស្សិតនឹងត្រូវបង់ថ្លៃសិក្សាពេញថ្លៃនៃតម្លៃសិក្សាតាមជំនាន់ជាក់ស្តែង។

ឈ.និស្សិតដែល "ព្យួរការសិក្សា" ខាងលើនេះ ដែលបានបង់ថ្លៃពេញ១ឆ្នាំសិក្សា ដោយមូលហេតុសមស្របណាមួយ នៅពេលចុះឈ្មោះចូលរៀនវិញជាថ្មី ប្រសិនបើទទួលការអនុញ្ញាតពីស.វ.ស និស្សិតនឹងត្រូវបង់ថ្លៃសិក្សាតែពាក់កណ្តាលនៃតម្លៃសិក្សាតាមជំនាន់ជាក់ស្តែង។

**ប្រការ ១០ ៖ ការលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិត**

និស្សិតនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលនឹងត្រូវបានលុបឈ្មោះចេញពីបញ្ជីនិស្សិតនៃស.វ.ស ប្រសិនបើនិស្សិតទាំងនោះពុំមាននៅសល់ពេលវេលា (ឆ្នាំ) គ្រប់គ្រាន់សម្រាប់បញ្ចប់ការសិក្សាក្នុងកម្រិតនីមួយៗរបស់ខ្លួនតាមការកំណត់ក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ។

និស្សិតដែលនៅសល់ពេលវេលា (ឆ្នាំ) ត្រឹមសម្រាប់តែបញ្ចប់កម្មវិធីសិក្សា និស្សិតនោះត្រូវធ្វើកិច្ចសន្យាទទួលស្គាល់ស្ថានភាពរបស់ខ្លួនមុននឹងអាចចុះឈ្មោះចូលរៀននៅឆ្នាំសិក្សាថ្មីបាន។

ចំពោះនិស្សិតស.វ.សណាបង្កទំនាស់ជាមួយ មន្ត្រីរាជការ បុគ្គលិក គ្រូ និងនិស្សិត ឬមានកំហុសផ្សេងៗក្នុងបរិវេណសាកលវិទ្យាល័យ ហើយត្រូវបានវាយតម្លៃ និងវិនិច្ឆ័យដោយគណៈកម្មការវិន័យស.វ.សថា មានកំហុស និស្សិតនោះនឹងអាចទទួលពិន័យ ឬត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតស.វ.ស ដោយមិនគិតបូករួមទាំងទោសកំហុសផ្លូវច្បាប់ផ្សេងទៀត។

**ប្រការ១១ ៖ ការកំណត់លក្ខខណ្ឌ "ត្រួតថ្នាក់"**

ត្រូវចាត់ទុកថា "ត្រួតថ្នាក់" ក្នុងករណីនិស្សិតបានចុះឈ្មោះចូលរៀន និងបង់ថ្លៃសិក្សាពេញលេញ (ទាំង២ ឆមាស) ព្រមទាំងមានលក្ខខណ្ឌណាមួយដូចខាងក្រោម៖

-ការសិក្សាគ្មានសុពលភាពដោយអវត្តមានលើសកំណត់ក្នុងម៉ោងសិក្សា ឬម៉ោងអនុវត្តបង្ហាញគ្រាប់ ឬ

-កម្មសិក្សាគ្មានសុពលភាព ឬ

-ធ្លាក់ការប្រឡងលើកទី២ ឬ

-អវត្តមានក្នុងពេលប្រឡងលើកទី២។

និស្សិតដែល "ត្រួតថ្នាក់" ខាងលើនេះ នៅពេលចុះឈ្មោះចូលរៀនវិញជាថ្មី ប្រសិនបើទទួលការអនុញ្ញាតពីស.វ.ស និស្សិតនឹងត្រូវបង់ថ្លៃសិក្សាតែពាក់កណ្តាលនៃតម្លៃសិក្សាតាមជំនាន់ជាក់ស្តែង។

**ប្រការ ១២ ៖ ការកំណត់លក្ខខណ្ឌនៃ "ការបោះបង់ការសិក្សា"**

ចំពោះនិស្សិតចាស់ ត្រូវចាត់ទុកថា "បោះបង់ការសិក្សា" ក្នុងករណីនិស្សិតដែលមានលក្ខខណ្ឌណាមួយដូចខាងក្រោម៖

-មិនបានចុះឈ្មោះចូលរៀន ឬ

-បានចុះឈ្មោះចូលរៀន ប៉ុន្តែមិនបានបង់ថ្លៃសិក្សាពេញលេញ (បង់ថ្លៃសិក្សាបានតែ១ ឆមាស ឬមិនបានបង់ថ្លៃសិក្សាទាំង២ ឆមាស)។

និស្សិតដែល "បោះបង់ការសិក្សា" ខាងលើនេះ នៅពេលចុះឈ្មោះចូលរៀនវិញជាថ្មី ប្រសិនបើទទួលការអនុញ្ញាតពីស.វ.ស និស្សិតនឹងត្រូវបង់ថ្លៃសិក្សាពេញថ្លៃនៃតម្លៃសិក្សាតាមជំនាន់ជាក់ស្តែង។

# ផ្នែកទី ៥
# អំពីវិន័យ និង សណ្តាប់ធ្នាប់

## ប្រការ ១៣ ៖ ក្នុងបរិវេណសាកលវិទ្យាល័យ

ក.និស្សិត និងអតីតនិស្សិតទាំងអស់មិនត្រូវ ៖

-ជក់បារី សេពគ្រឿងស្រវឹង និងប្រើប្រាស់ ឬ ជួញដូរគ្រឿងញៀន។

-យកអាវុធ ជាតិផ្ទុះគ្រប់ប្រភេទ ឬ នាំមិត្តភក្តិខាងក្រៅ ចូលក្នុងបរិវេណសាកលវិទ្យាល័យ។

-លេងល្បែងស៊ីសងគ្រប់ប្រភេទ ឬ ប្រព្រឹត្តអំពើពាលាដែលនាំឱ្យខុសប្រពៃណីជាតិ។

-ធ្វើសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងផលប្រយោជន៍របស់សាកលវិទ្យាល័យ និង សង្គមជាតិ។

-ស្រែកឡូឡា ឬប្រើពាក្យអាសអាភាស អាសគ្រាម និងអាកប្បកិរិយាមិនសមរម្យ។

-ប្រព្រឹត្តអំពើអានាចារតាមគ្រប់រូបភាព។

-ធ្វើឱ្យបាត់បង់សោភ័ណភាព ឬប៉ះពាល់បរិស្ថាន ដូចជាសរសេរ គូសវាស ឬធ្វើឱ្យប្រឡាក់ជញ្ជាំង លើតុ លើទ្វារ លើបង្អួចនៃបន្ទប់រៀន ចោលសំរាម ខាកស្តោះលើជណ្តើរ ឬកម្រាលឥដ្ឋ ។ល។

-លុប ឬហែកលិខិតស្នាមទាំងឡាយដែលសាកលវិទ្យាល័យបានបិទផ្សាយជាសាធារណៈ។

-ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិសាកលវិទ្យាល័យ។

-បន្ទោរបង់ក្រៅបង្គន់។

-តុបតែងខ្លួនហួសហេតុខុសប្លែកពីប្រក្រតី។

-ធ្វើសកម្មភាពនានាដោយមិនបានទទួលការអនុញ្ញាតពីគណៈគ្រប់គ្រងសាកលវិទ្យាល័យជាមុន និង សកម្មភាពទាំងឡាយណាដែលផ្ទុយពីច្បាប់ដែលមានជាធរមាន។

ខ.និស្សិតត្រូវរាយការណ៍ជាបន្ទាន់ មកការិយាល័យរដ្ឋបាលមហាវិទ្យាល័យ/សាលា/ផ្នែក/ដេប៉ាតឺម៉ង់ ឬ ភ្នាក់ងារសន្តិសុខស.រ.ស រាល់មានហេតុការណ៍មិនប្រក្រតីនានាដូចជា ៖

-មានអគ្គីភ័យ ធ្លាយទឹក ឬការខូចខាតហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

-និស្សិតមានជំងឺដែលត្រូវសង្គ្រោះជាបន្ទាន់។

-និស្សិតឈ្លោះប្រកែកគ្នា ឬវាយតប់គ្នា។

-មានអំពើចោរកម្ម។

-មានសមាសភាពមិនល្អ ឬជនសង្ស័យចូលក្នុងបរិវេណស.រ.ស ។ល។

**គ.**និស្សិតគ្រប់រូបត្រូវចូលរួមចំណែកសន្សំសំចៃ ទឹក ភ្លើង និង ជួយថែរក្សាទ្រព្យសម្បត្តិសាកលវិទ្យាល័យ និងថែរក្សាអនាម័យ សន្តិសុខ និង សណ្តាប់ធ្នាប់ក្នុងបរិវេណសាកលវិទ្យាល័យ។

**ឃ.**ក្នុងបរិបទទប់ស្កាត់ការរីករាលដាលកូវីត ១៩ និស្សិតត្រូវពាក់ម៉ាស រក្សាគម្លាតសង្គម រក្សាអនាម័យ និង អនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមលំហូរ/គន្លងចេញ-ចូលតាមការកំណត់របស់ស.រ.ស។

**ង.**ករណីនិស្សិតមិនអនុវត្តតាមចំណុចណាមួយក្នុងចំណុច "ក, ខ, គ និងឃ" នៃប្រការ១៣ នេះ និស្សិតទាំងនោះនឹង៖

-ករណីនិស្សិតមិនអនុវត្តលើកទី១៖ ទទួលការណែនាំជាលាយលក្ខអក្សរពីផ្នែកកិច្ចការនិស្សិតរបស់មហាវិទ្យាល័យ/សាលា/ផ្នែក/ដេប៉ាតឺម៉ង់ ព្រមទាំងបញ្ជូនរបាយការណ៍មកព្រឹទ្ធបុរស/នាយក ឬប្រធាន នៃមហាវិទ្យាល័យ/សាលា/ផ្នែក/ដេប៉ាតឺម៉ង់ទុកជាឯកសារ។

-ករណីនិស្សិតនៅតែមិនអនុវត្តជាលើកទី២៖ ទទួលការព្រមានជាលាយលក្ខអក្សរពីគណៈកម្មការវិន័យរបស់មហាវិទ្យាល័យ/សាលា/ផ្នែក/ដេប៉ាតឺម៉ង់ ព្រមទាំងអនុវត្តតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន និងបញ្ជូនរបាយការណ៍មកសាកលវិទ្យាធិការទុកជាឯកសារ។

**ប្រការ ១៤ ៖ ក្នុងថ្នាក់រៀនទ្រឹស្តី និងអនុវត្តបន្ទាញគ្រាប់**

ក. និស្សិតទាំងអស់ត្រូវ ៖

-គោរពពេលវេលាតាមកាលវិភាគរបស់មហាវិទ្យាល័យ/សាលា/ដេប៉ាតឺម៉ង់/ផ្នែកឱ្យបានម៉ឺងម៉ាត់។ ករណីមកយឺតលើសពី ១៥ នាទី មិនអនុញ្ញាតឱ្យចូលថ្នាក់សិក្សាទ្រឹស្តី និងអនុវត្តគ្រាប់ឡើយ។

-យកចិត្តទុកដាក់រៀនសូត្រ រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និង មិនធ្វើអ្វីរំខានដល់មិត្តភក្តិ។ គ្រូដែលបង្រៀនមានសិទ្ធិបណ្តេញនិស្សិតដែលបង្កការរំខានក្នុងម៉ោងសិក្សាចេញពីថ្នាក់រៀន។

-រក្សាភាពស្ងៀមស្ងាត់ និងសម្តែងនូវអាកប្បកិរិយាថ្លៃថ្នូរ ពេលគ្រូ ឬភ្ញៀវអញ្ជើញចូលក្នុងថ្នាក់រៀន។

-រក្សាភាពស្ងៀមស្ងាត់ ហើយប្រធាន ឬអនុប្រធានថ្នាក់ត្រូវមកទំនាក់ទំនង និង ទទួលព័ត៌មានពីការិយាល័យសិក្សា ឬការិយាល័យរដ្ឋបាល ករណីគ្រូអវត្តមាន ឬមកយឺតលើសពី ១៥នាទី នៃម៉ោងកំណត់។

-ប្រកាន់អាកប្បកិរិយាសមរម្យ មិនត្រូវប្រឡែងគ្នា ស្រែកឡូឡា ឬប្រើពាក្យអាសអាភាស អាសគ្រាម និងអាកប្បកិរិយាមិនសមរម្យ ឬឈ្លោះប្រកែកគ្នាឡើយ ក្នុងពេលសម្រាកចន្លោះម៉ោងសិក្សានីមួយៗ។

-សុំអនុញ្ញាតពីគ្រូដែលកំពុងបង្រៀនពេលចេញក្រៅថ្នាក់ ឬពេលចេញទៅផ្ទះក្នុងករណីមានធុរៈចាំបាច់ ឬមានជំងឺផ្ទាល់ខ្លួន ហើយត្រូវអនុវត្តតាមប្រការ “៨ ស្តីពីអវត្តមាន” ខាងលើ។

-ក្នុងបរិបទទប់ស្កាត់ការរីករាលដាលកូវីត ១៩ និស្សិតត្រូវពាក់ម៉ាស រក្សាគម្លាតសង្គម រក្សាអនាម័យ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមការកំណត់របស់ស.វ.ស។

-ក្នុងពេលសិក្សាពីចម្ងាយ (Online) និស្សិតត្រូវ៖

- ស្លៀកពាក់សមរម្យ។
- រកទីកន្លែងសមស្រប ដោយចៀសវាងសម្លេងរំខានខាងក្រៅ ចូលក្នុងក្រុមសិក្សា។
- ចូលរួមសិក្សាដោយយកចិត្តទុកដាក់។

ខ. និស្សិតទាំងអស់មិនត្រូវ ៖

-នាំមិត្តភ័ក្តិពីក្រៅមកចូលក្នុងថ្នាក់រៀនរបស់ខ្លួនឡើយក្នុងពេលកំពុងសិក្សា។

-បើកសម្លេងរោទ៍ទូរស័ព្ទដៃ ឬ វិទ្យុទាក់ទងក្នុងពេលសិក្សា។

-បរិភោគអាហារ ឬភេសជ្ជៈនានាក្នុងថ្នាក់រៀនទាំងក្នុងម៉ោងរៀន ឬក្រៅម៉ោងរៀន។

-ប្រារព្ធពិធី ឬសកម្មភាពនានាក្នុងថ្នាក់រៀនដោយគ្មានការអនុញ្ញាតជាមុនពីថ្នាក់ដឹកនាំមហាវិទ្យាល័យ/សាលា/ដេប៉ាតឺម៉ង់/ផ្នែកទាំងក្នុងម៉ោងរៀន ឬក្រៅម៉ោងរៀន។

**ប្រការ ១៥ ៖ ក្នុងបណ្ណាល័យ**

និស្សិតទាំងអស់ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យ។

# ផ្នែកទី ៦
# អំពីការប្រឡង

**ប្រការ ១៦ ៖ មុនពេលប្រឡង**

និស្សិតទាំងអស់ត្រូវ ៖

-ពិនិត្យផ្ទៀងផ្ទាត់បញ្ជីកំណត់សុពលភាពប្រឡងដែលបានបិទប្រកាសដោយមហាវិទ្យាល័យ សាលា ផ្នែក ដេប៉ាតឺម៉ង់ឱ្យបានមុនកាលបរិច្ឆេទនៃការប្រឡងនីមួយៗ។

-តាមដានពិនិត្យកាលវិភាគប្រឡង ដែលបានផ្សព្វផ្សាយដោយមហាវិទ្យាល័យ សាលា ផ្នែក ដេប៉ាតឺម៉ង់ឱ្យបានមុនកាលបរិច្ឆេទនៃការប្រឡងនីមួយៗ។

-ក្នុងករណីប្រឡងពីចម្ងាយ (Online) និស្សិតត្រូវទទួលខុសត្រូវ រកកន្លែង ឧបករណ៍ និងប្រព័ន្ធអ៊ីនធឺណែតសមស្របជាមុនសម្រាប់ការប្រឡង។

**ប្រការ ១៧ ៖ ពេលចូលប្រឡង**

-និស្សិតដែលមានសិទ្ធប្រឡងដែលមានឈ្មោះក្នុងបញ្ជីកំណត់សុពលភាពប្រឡង ទើបអាចចូលប្រឡងបាន។

-និស្សិតគ្រប់រូបត្រូវអនុវត្តតាមការណែនាំ/បទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រឡង ដែលកំណត់ដោយមហាវិទ្យាល័យ/សាលា/ដេប៉ាតឺម៉ង់/ផ្នែក។

-និស្សិតគ្រប់រូបត្រូវចូលប្រឡងទៅតាមកាលវិភាគប្រឡងដែលកំណត់ដោយមហាវិទ្យាល័យ/សាលា/ដេប៉ាតឺម៉ង់/ផ្នែក។

-និស្សិតគ្រប់រូបត្រូវមានប័ណ្ណសម្គាល់ខ្លួននិស្សិត និងស្លៀកពាក់ឯកសណ្ឋាននិស្សិត និងអនុវត្តតាមការណែនាំផ្សេងៗទៀតរបស់គណៈកម្មការប្រឡង។ ករណីនិស្សិតគ្មានបណ្ណសម្គាល់ខ្លួននិស្សិត (ភ្លេច ឬ បាត់) ត្រូវសុំការអនុញ្ញាតពីគណៈ-កម្មការប្រឡង។

-និស្សិតត្រូវមានវត្តមាន១៥ នាទីមុនម៉ោងប្រឡងដែលកំណត់ដោយគណៈកម្មការប្រឡង។

-និស្សិតដែលមកយឺតចាប់ពី១៥ នាទីឡើងទៅក្រោយចេញវិញ្ញាសា គឺមិនអនុញ្ញាតឱ្យប្រឡងហើយចាត់ទុកថា "អវត្តមាន " លើមុខវិជ្ជានោះ។

-ក្នុងបរិបទទប់ស្កាត់ការរីករាលដាលកូវីត ១៩ និស្សិតត្រូវពាក់ម៉ាស រក្សាគម្លាតសង្គម រក្សាអនាម័យ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមលំហូរ/គន្លងចេញ-ចូលតាមការកំណត់របស់គណៈកម្មការប្រឡង។

**ប្រការ ១៨ ៖ ក្នុងពេលប្រឡង**

និស្សិតទាំងអស់ត្រូវ ៖

-អនុវត្តតាមការណែនាំ/បទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រឡង ដែលកំណត់ដោយមហាវិទ្យាល័យ/សាលា/ដេប៉ាតឺម៉ង់/ផ្នែក។

-គោរពវិន័យ ពាក់បណ្ណសំគាល់ខ្លួន និងអនុវត្តតាមការណែនាំរបស់អនុរក្ស ឬតាមការកំណត់ដោយគណៈ-កម្មការប្រឡង។

**ប្រការ ១៩ ៖ ការវាយតម្លៃនៃការប្រឡង**

-ការវាយតម្លៃលើគ្រប់ប្រភេទនៃការប្រឡងនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលត្រូវអនុវត្តតាមវិធាននៃការវាយតម្លៃនៃកម្មវិធីសិក្សានីមួយៗ ឬតាមការជូនដំណឹងដោយឡែករបស់ស.វ.ស ឬតាមលិខិតបទដ្ឋានគតិយុត្តិនានារបស់ក្រសួងសុខាភិបាល។

-និស្សិតដែលអវត្តមានក្នុងពេលប្រឡង ត្រូវចាត់ទុកថាធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ទោះបីអវត្តមានដោយមូលហេតុណាមួយក៏ដោយ។

## ផ្នែកទី ៧
## ពិន័យនៅពេលប្រឡង

**ប្រការ ២០ ៖ ករណីមានឯកសារ ឬ សំណៅផ្សេងៗ**

ករណីមានឯកសារ ឬ សំណៅផ្សេងៗ ក្រៅពីការអនុញ្ញាតរបស់អនុរក្សនៅពេលប្រឡង និស្សិតត្រូវទទួលការព្រមាន ឬការពិន័យដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃការប្រឡងនីមួយៗ។

**ប្រការ ២១ ៖ ការអង្គុយខុសលេខតុ/កុំព្យូទ័រ ឬ បញ្ចូលទិន្នន័យដែលមិនមែនជាទិន្នន័យរបស់សាមីខ្លួនក្នុងប្រព័ន្ធកុំព្យូទ័រ**

ករណីការអង្គុយខុសលេខតុ/កុំព្យូទ័រពីតាមការណែនាំរបស់អនុរក្ស ឬបញ្ចូលទិន្នន័យដែលមិនមែនជាទិន្នន័យរបស់សាមីខ្លួនក្នុងប្រព័ន្ធកុំព្យូទ័រ និស្សិតត្រូវទទួលការបញ្ឈប់ការប្រឡងភ្លាមតាមការសម្រេចរបស់គណកម្មការប្រឡង។

**ប្រការ ២២ ៖ ការប្រគល់សន្លឹកកិច្ចការជាក្រដាស**

ក្នុងករណីប្រឡងដែលប្រើសន្លឹកកិច្ចការជាក្រដាស និស្សិតណាដែលមិនបានប្រគល់សន្លឹកកិច្ចការដល់អនុរក្សនៅពេលចប់ម៉ោងប្រឡង ត្រូវបានពិន្ទុសូន្យ។

**ប្រការ ២៣ ៖ ការប្រព្រឹត្តកំហុសនានាដែលផ្ទុយពីបទបញ្ជាផ្ទៃក្នុងនៃការប្រឡង**

ក្នុងករណីនិស្សិត ប្រព្រឹត្តកំហុសនានាដែលផ្ទុយពីបទបញ្ជាផ្ទៃក្នុងនៃការប្រឡង និស្សិតនឹងត្រូវបញ្ឈប់ពីការប្រឡងជាបន្ទាន់ ចំពោះមុខវិជ្ជាកំពុងប្រឡង ។

និស្សិតនឹងចាត់ទុកថាធ្លាក់ដោយស្វ័យប្រវត្តិចំពោះមុខវិជ្ជាដែលត្រូវបានបញ្ឈប់ការប្រឡងនោះ។

**ប្រការ ២៤ ៖ ករណីបង្កចំនាស់ក្នុងពេលប្រឡង**

ចំពោះនិស្សិតទាំងឡាយណាដែលបង្កចំនាស់ក្នុងពេលប្រឡង គណៈកម្មការប្រឡងមានសិទ្ធិបញ្ឈប់ ការប្រឡងរបស់និស្សិតនោះ ចាប់ពីមួយមុខវិជ្ជា រហូតដល់គ្រប់មុខវិជ្ជាក្នុងសម័យប្រឡងនោះ ឬ ស្នើសុំលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតស.វ.ស អាស្រ័យទៅតាមទំហំនៃកំហុសរបស់និស្សិត។

**ប្រការ ២៥ ៖ ការបែកចោលសន្លឹកកិច្ចការប្រឡង ឬការបង្កការខូចខាតសម្ភារៈប្រឡងដោយចេតនា**

ប្រសិនបើមានការបែកចោលសន្លឹកកិច្ចការប្រឡង ឬការបង្កការខូចខាតសម្ភារៈប្រឡងដោយចេតនា និស្សិតនឹងត្រូវបញ្ឈប់ការប្រឡងគ្រប់មុខវិជ្ជាទាំងអស់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តទៅដោយគណៈកម្មការប្រឡង និង ទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ ២៦ ៖ ការប្រឡងជំនួស**

ក្នុងករណីមាននិស្សិតប្រឡងជំនួស ឬប្រឡងជួសនិស្សិតម្នាក់ទៀត និស្សិតទាំងនោះ (ទាំងអ្នកជួយគេ និង អ្នកត្រូវគេជួយ) ត្រូវទទួលពិន័យពីគណៈកម្មការប្រឡងតាមគោលការណ៍ប្រឡងនានាចាប់ពីបញ្ឈប់ការប្រឡងគ្រប់មុខវិជ្ជាទាំងអស់ដែលកំពុងប្រព្រឹត្តទៅរហូតដល់ស្នើសុំលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតស.វ.ស និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

## ផ្នែកទី ៨
## អំពី សិល្បៈ និង កីឡា

**ប្រការ ២៧ ៖ អំពីសិល្បៈ**

ស.វ.សលើកទឹកចិត្តនិស្សិតគ្រប់រូបចូលរួមក្នុងសកម្មភាពសិល្បៈ វប្បធម៌ ដែលរៀបចំឡើង ឬសម្របសម្រួលដោយស.វ.សដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការលើកស្ទួយ និង ការពារសិល្បៈ វប្បធម៌ ប្រពៃណីខ្មែរ។

**ប្រការ ២៨ ៖ អំពីកីឡា**

ស.វ.ស លើកទឹកចិត្តនិស្សិតគ្រប់រូបចូលរួមលើសកម្មភាពកីឡាគ្រប់ប្រភេទដែលរៀបចំឡើង ឬសម្របសម្រួលដោយស.វ.សដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យកីឡានៅកម្ពុជា។

## ផ្នែកទី ៩
## អំពីការចូលរួមក្នុងសកម្មភាពផ្សេងៗ

**ប្រការ ២៩ ៖** ស.វ.ស លើកទឹកចិត្តនិស្សិតគ្រប់រូបចូលរួមក្នុងសកម្មភាពកាកបាទក្រហម កាយរិទ្ធ ឬ សកម្មភាពគាំទ្រសង្គមផ្សេងៗទៀតដែលទាក់ទងនឹងសុខភាព និងសុខមាលភាពប្រជាពលរដ្ឋ។ ក្នុងករណីសកម្មភាពនោះមិនបានរៀបចំ ឬសម្របសម្រួលដោយ ស.វ.ស និស្សិតត្រូវសុំការអនុញ្ញាតជាលាយលក្ខណអក្សរជាមុនពីស.វ.ស ក្នុងករណីសកម្មភាពទាំងនោះធ្វើជាន់គ្នាក្នុងម៉ោងសិក្សា ឬម៉ោងកម្មសិក្សា។

**ប្រការ ៣០ ៖** និស្សិតត្រូវចូលរួមតាមការចាត់តាំងរបស់សាកលវិទ្យាល័យក្នុងកម្មវិធីផ្សេងៗដែលរៀបចំដោយស.វ.ស ឬតាមការស្នើសុំពីស្ថាប័ននានាដោយមានការសម្របសម្រួលពីស.វ.ស។

**ប្រការ ៣១ ៖** រាល់កម្មវិធីនានាដែលរៀបចំឡើងដោយនិស្សិតស.វ.ស ឬកម្មវិធីដែលគ្រោងនឹងប្រើប្រាស់ឈ្មោះស.វ.ស និស្សិតត្រូវស្នើសុំការអនុញ្ញាតជាមុនពីស.វ.ស។

## ផ្នែកទី ១០
## ឱសានវាទនៃបញ្ញត្តិ

**ប្រការ ៣២ ៖** បទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែទៅតាមតម្រូវការ និងកាលៈទេសៈចាំបាច់។ បទបញ្ជាផ្ទៃក្នុងនិស្សិតទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីបទបញ្ជាផ្ទៃក្នុងនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣៣ ៖** បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រការ ៣៤ ៖** ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក សាស្ត្រាចារ្យ និស្សិត ព្រមទាំងសមាជិក-សមាជិកា នៃគណៈកម្មការផ្សេងៗ ត្រូវតែអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធិភាពខ្ពស់ ៕

ថ្ងៃ............ខែ...........ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**សាកលវិទ្យាធិការ**

**សាស្ត្រាចារ្យ.សាផុន-វឌ្ឍនៈ**

**ចម្លងជូន ៖**

-ខុទ្ទកាល័យក្រសួងសុខាភិបាល

-ខុទ្ទការល័យក្រសួងអប់រំ យុវជន និងកីឡា "ដើម្បីជូនជ្រាប"

-ក្រុមប្រឹក្សាភិបាលស.វ.ស "ដើម្បីជូនជ្រាប"

-នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស

-នាយកដ្ឋានគ្រប់គ្រងបុគ្គលិកក្រសួងសុខាភិបាល

-មហាវិទ្យាល័យវេជ្ជសាស្ត្រ

-មហាវិទ្យាល័យឱសថសាស្ត្រ

-មហាវិទ្យាល័យទន្តវេទនសាស្ត្រ

-សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ

-សាកលវិទ្យាធិការដ្ឋានស.វ.ស

-ផ្សព្វផ្សាយដល់និស្សិត "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**

# លិខិតថ្លែងអំណរគុណ

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលដែលបានខិតខំចំណាយនូវពេលវេលារៀបចំ ចងក្រង ពិនិត្យ និងកែសម្រួលបទបញ្ញាផ្ទៃក្នុងនិស្សិតឆ្នាំ២០២១នេះ ដែលមានរាយនាមដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តមសាស្ត្រាចារ្យ | **សាផុន វឌ្ឍនៈ** | សាកលវិទ្យាធិការនៃស.វ.ស |
| ២- ឯកឧត្តមសាស្ត្រាចារ្យរង | **ហង្ស ច័ន្ទធរ:** | សាកលវិទ្យាធិការរងនៃស.វ.ស |
| ៣- លោកសាស្ត្រាចារ្យរង | **សេង សុភាព** | សាកលវិទ្យាធិការរងនៃស.វ.ស |
| ៤- លោកសាស្ត្រាចារ្យជំនួយ | **ម៉ម សុវត្ថា** | សាកលវិទ្យាធិការរងនៃស.វ.ស |
| ៥-លោកសាស្ត្រាចារ្យ | **ឈាង សេនា** | ព្រឹទ្ធបុរសមហាវិទ្យា.ឱសថសាស្ត្រនៃស.វ.ស |
| ៦- លោកសាស្ត្រាចារ្យជំនួយ | **ប៊ុនចាន់ យុត្តិរុង** | ព្រឹទ្ធបុរសមហាវិទ្យា.វេជ្ជសាស្ត្រនៃស.វ.ស |
| ៧- លោកសាស្ត្រាចារ្យ | **សេង រស់សមិទ្ធិ** | ព្រឹទ្ធបុរសម.ទន្តវេទនសាស្ត្រនៃស.វ.ស |
| ៨- លោកសាស្ត្រាចារ្យជំនួយ | **តាន់ វី** | នាយកសាលាបច្ចេកទេសថែទាំវេជ្ជ.នៃស.វ.ស |
| ៩- លោកសាស្ត្រាចារ្យជំនួយ | **នាក់ មករា** | ប្រធានសាកលវិទ្យាធិការដ្ឋាននៃស.វ.ស |
| ១០- លោកសាស្ត្រាចារ្យជំនួយ | **អៀង រ័ត្នមុនី** | ព្រឹទ្ធបុរសរងម.ឱនៃស.វ.ស |
| ១១- លោកសាស្ត្រាចារ្យជំនួយ | **គីម សុធា** | ព្រឹទ្ធបុរសរងម.ឱនៃស.វ.ស |
| ១២- លោកវេជ្ជបណ្ឌិត | **ឡេង វេងសៃ** | នាយករងសាលាបច្ចេកទេសថែទាំវេជ្ជ.នៃស.វ.ស |
| ១៣- លោក | **លឹម វុឌ្ឍី** | នាយករងសាលាបច្ចេកទេសថែទាំវេជ្ជ.នៃស.វ.ស |
| ១៤- លោកស្រីបរិ.ជាន់ខ្ពស់ | **ស៊ុយ សុវណ្ណធីតា** | ប្រធានផ្នែកសុខភាពសាធារណៈនៃស.វ.ស |
| ១៥- លោកសាស្ត្រាចារ្យរង | **យ៉ែម សុផល** | ប្រធានការិយាល័យសិក្សាម.វ.ទនៃស.វ.ស |
| ១៦- លោកស្រី | **ប៉ែន សុខារី** | ប្រធានការិយាល័យលិខិតបទដ្ឋាននិស្សិត |
| ១៧- លោកវេជ្ជបណ្ឌិត | **ស៊ិន វឌ្ឍនៈ** | អនុប្រធានការិយាល័យសិក្សាម.វ.វនៃស.វ.ស |
| ១៨- លោក | **ផាន ស៊ាងហួ** | មន្ត្រីសាកលវិទ្យាធិការដ្ឋាននៃស.វ.ស |
| ១៩- លោក | **ហ៊ុយ ឆេងតារាភាព** | មន្ត្រីសាកលវិទ្យាធិការដ្ឋាននៃស.វ.ស |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

UNIVERSITE DES SCIENCES DE LA SANTE

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

លេខ:.........០៥៨៦.........ស.វ.ស

រាជធានីភ្នំពេញ ថ្ងៃទី...០៥ ខែ...កុម្ភៈ ឆ្នាំ២០១៧

# លិខិតបង្គាប់ការ

## សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

**យោង៖** -ការចាំបាច់របស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

-លិខិតលេខ ០០៥ស.វ.ស ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

**សម្រេច**

បង្កើតក្រុមការងារពិនិត្យ និងរៀបចំចងក្រងឡើងវិញ នូវបទបញ្ញាផ្ទៃក្នុងរបស់ និស្សិត នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១-លោកសាស្ត្រាចារ្យរង ហង្ស ច័ន្ទវរៈ | ប្រធាន |
| ២-លោកវេជ្ជបណ្ឌិត អៀង វត្ថមុនី | អនុប្រធាន |
| ៣-លោកវេជ្ជបណ្ឌិត ឡេង វេងសៃ | អនុប្រធាន |
| ៤-លោកសាស្ត្រាចារ្យជំនួយ នាក់ មករា | សមាជិក |
| ៥-លោក លឹម វុឌ្ឍី | សមាជិក |
| ៦-លោកបណ្ឌិត យឹម កែវវឌ្ឍនៈ | សមាជិក |
| ៧-លោកសាស្ត្រាចារ្យរង យ៉ែម សុផល | សមាជិក |
| ៨-លោកវេជ្ជបណ្ឌិត ស៊ិន វឌ្ឍនៈ | សមាជិក |
| ៩-លោក ផាន ស៊ាងហួ | លេខា |
| ១០-លោក ហ៊ុយ ឆេងតាពភាព | លេខា |

សាស្ត្រាចារ្យ បណ្ឌិត វេជ្ជបណ្ឌិត លោក-លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអនុវត្តភារកិច្ចនេះឲ្យមានប្រសិទ្ធិភាពខ្ពស់បំផុត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅរហូតចប់ភារកិច្ច។

សាស្ត្រាចារ្យ.សាផុន-វឌ្ឍនះ

**កន្លែងទទួល៖**

-មហាវិទ្យាល័យ/សាលា
-សាកលវិទ្យាធិការដ្ឋាន
-ការិយាល័យគណនេយ្យ
-សាមីខ្លួន(ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ